# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៣៤៧ ព.ណ.ស.ជពកព

ថ្ងៃអង្គារ ៥កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២៦

## សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនឱ្យបានជ្រាបថា **ពិព័រណ៌ម្ហូបអាហារ និងភេសជ្ជៈ ឆ្នាំ២០២៦** «SIAL CHINA 2026» នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨-២០ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលតាំងពិព័រណ៌អន្តរជាតិថ្មីសៀងហៃ ទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដែលព្រឹត្តិការណ៍ពិព័រណ៌នេះ នឹងមានអ្នកចូលរួមតាំងពិព័រណ៌ប្រមាណ៥,០០០នាក់ មកពី៧៥ប្រទេស និងរំពឹងថាមានអ្នកទស្សនាចំនួន ១៧០,០០០នាក់។

**ពិព័រណ៌ម្ហូបអាហារ និងភេសជ្ជៈ ឆ្នាំ២០២៦ «SIAL CHINA 2026»** គឺជាព្រឹត្តិការណ៍ពិព័រណ៌ម្ហូបអាហារ និងភេសជ្ជៈធំបំផុតលំដាប់ពិភពលោក ដែលជាវេទិកាសម្រាប់ផ្សព្វផ្សាយសម្រាប់ក្រុមហ៊ុនម្ហូបអាហារ និងភេសជ្ជៈ ដែលកំពុងស្វែងរកការពង្រីកខ្លួនទៅទីផ្សារក្រៅប្រទេស និងជំរុញអាជីវកម្មម្ហូបអាហារ តាមរយៈការចែករំលែកការយល់ដឹង និងនិន្នាការថ្មីៗ ក៏ដូចជាការបង្ហាញអំពីម្ហូបអាហារផ្សេងៗទៅតាមតំបន់ និងតាមប្រទេស ដើម្បីផ្សារភ្ជាប់អ្នកតាំងពិព័រណ៌និងអ្នកទិញ និងផ្ដល់ឱកាសដល់ការបង្កើនបណ្ដាញទំនាក់ទំនង។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្មសូមអញ្ជើញ លោក-លោកស្រី ជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន ដែលមានបំណងចង់ចូលរួមតាំងបង្ហាញនូវផលិតផល ដែលជាប្រភេទអាហារ និងភេសជ្ជៈ ក្នុងព្រឹត្តិការណ៍ពិព័រណ៌ខាងលើ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៌ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានអាសយដ្ឋានដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងសូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួល តាមរយៈទូរស័ព្ទលេខ +៨៥៥ ១៦ ៤១៦ ៨២៥ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល chao.katphuoy@moc.gov.kh។

សូមអរគុណ!

ស្រមាប់ចុះឈ្មោះ:

https://go.gov.kh/moc/cx3a9e

GO.gov.KH

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°1327.MOC.D/T.PEA

Phnom Penh, 21 April 2026

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform traders, producers, investors, and the public that "SIAL CHINA 2026" will be held from 18-20 May 2026 at Shanghai New International Expo Center, Shanghai, People's Republic of China. This expo is expected to host approximately 5,000 exhibitors from 75 countries and an estimated 170,000 visitors.

"SIAL CHINA 2026" is the world's largest food and beverage expo, providing a platform for food and beverage companies seeking to expand into international markets and enhance their businesses by sharing insights and emerging industry trends, as well as showcasing regional and national food products to connect exhibitors and buyers and foster valuable business partnerships.

In this regard, the Ministry of Commerce would like to invite traders, producers, investors, and the public who are interested in showcasing their food and beverage products at this expo to please contact the Department of Trade Promotion and Exhibition Affairs, Directorate General of Trade Policy and Trade Promotion, the Ministry of Commerce, at Lot No. 19-16, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or via:

Tel: +855 16 416 825

MOC Call Center: 1266

E-mail: chao.katphuoy@moc.gov.kh.

For Registration

THANK YOU!

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla,
Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469